ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ៦/៤៦ MOC / M 2003

# ប្រកាស

## ស្តីពីការបង្កើតបន្ថែមការិយាល័យមួយចំណុះ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ័ណ-អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិត លេខ ១០៩៣ សជណ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតមជ្ឈមណ្ឌលទំនាក់ទំនង ផ្តល់ពត៌មានសំរាប់អនុវត្តកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មអន្តរជាតិ
- តាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## <u>សំរេច</u>

**ប្រការ១:**_

បង្កើតបន្ថែម ការិយាល័យ "ផ្តល់ចំលើយការអនុវត្តវិធានការណ៍អនាម័យ និងភូតគាមអនាម័យ" ស្ថិតក្រោមនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ័ណ-អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល" ។

**ប្រការ២:**_

ការិយាល័យផ្តល់ចំលើយផ្នែកអនុវត្តវិធានការណ៍អនាម័យ និងភូតគាមអនាម័យ មានភារកិច្ចដូចខាងក្រោម ៖-

- ទទួលផ្តល់ពត៌មាន ពាក់ព័ន្ធ នឹងការអនុវត្តនីវិធានការណ៍អនាម័យ និងភូតគាម អនាម័យ ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ
- សំរបសំរួល សហការ ប្រមូលផ្តុំពត៌មាន ជាមួយកូដិចជាតិ និងក្រសួងពាក់ព័ន្ធក្នុងការផ្តល់ចម្លើយជូនលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក
- តាមដាន ប្រមូលផ្តុំពត៌មានថ្មីៗ អំពីបាតុភាពផ្នែកវិធានការណ៍ អនាម័យ និងភូតគាមអនាម័យ ជាក់លាក់ដែលមានប្រយោជន៍ដល់កម្ពុជា នៅបណ្តាប្រទេស
- ផ្តល់គំនិតជូនលេខាធិការដ្ឋានគណៈកម្មាធិការកូដិចជាតិ អំពីផលប៉ះពាល់ដល់កម្ពុជា នៃបណ្តាការងារកសាងស្តង់ដារម្ហូបអាហារ បញ្ហាត្រួតពិនិត្យម្ហូបអាហារ និងបញ្ហាភូតគាមអនាម័យ

- ធ្វើការផ្សព្វផ្សាយ អនុវត្តក្នុងប្រទេសនូវពត៌មានអំពីបណ្តឹងវិធានការទាក់ទងនឹងអនាម័យ និង ភូតគាមអនាម័យ
- ជំនួយការងារផ្នែកលេខាធិការ និងរដ្ឋបាលសំរាប់លេខាធិការដ្ឋានគណៈកម្មាធិការ កូដិចជាតិ
- ទទួលរាល់ការងារដែលលេខាធិការដ្ឋានគណៈកម្មាធិការកូដិចជាតិ និងនាយកដ្ឋានកាំកុងត្រូលប្រគល់អោយ ។

**ប្រការ៣:**

ការិយាល័យផ្តល់ចំលើយការអនុវត្តវិធានការណ៍អនាម័យ និងភូតគាមអនាម័យ ត្រូវដឹកនាំដោយ ប្រធានការិយាល័យមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ៤:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៥:**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនិហារ៉ណេ-អាហារ៉ណ និងបង្ក្រាបការក្លែងបន្លំ និង ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកូដិចជាតិ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់នាយកដ្ឋាន មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ